FACTSHEET

ក្រសួងអប់រំរដ្ឋ NSW

Parent, carer and student factsheet

**No prohibited knives at school**

ខិត្តប័ណ្ណព័ត៌មានសម្រាប់ឪពុកម្ដាយ អ្នកថែទាំ និងសិស្ស

# មិនត្រូវមានកាំបិតដែលបានហាមឃាត់នៅសាលារៀនឡើយ

រដ្ឋ NSW មានច្បាប់ហាមឃាត់កាំបិតដ៏តឹងរ៉ឹងបំផុត នៅក្នុងប្រទេសអូស្ត្រាលី។ វាប្រឆាំងនឹងច្បាប់ ចំពោះសិស្សមានកាំបិតដែលបានហាមឃាត់នៅទីសាធារណៈ ឬនៅសាលារៀន។ ការពិន័យអប្បបរមាគឺពិន័យជាទឹកប្រាក់ចំនួន $4,400 ការជាប់ពន្ធនាគាររយៈពេល 4 ឆ្នាំ ឬទាំងពីរនេះ។ ការផាកពិន័យអតិបរមាគឺ $11,000។

## មិនអនុញ្ញាតឱ្យមានកាំបិតដែលបានហាមឃាត់នៅសាលារៀនឡើយ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ

ដោយសារគោលនយោបាយរបស់សាលាត្រូវបានរៀបចំឡើង ដើម្បីរក្សាសុវត្ថិភាពសិស្សទាំងអស់ ដូច្នេះគ្មានកាំបិតប្រភេទណាមួយត្រូវបានអនុញ្ញាតឱ្យមាននៅសាលារៀនឡើយ រួមមានកាំបិតផ្ទាត់ កាំបិតស្នៀត កាំបិតចាក់ កាំបិតស្នាប់មុខស្រួច កាំបិតមេអំបៅ កាំបិតផ្កាយ ឬវត្ថុណាមួយដែលអាចប្រើជាអាវុធបាន (ដូចជាពន្លាក)។

ប្រសិនបើសិស្សម្នាក់ត្រូវបានគេរកឃើញថាមាន ឬកាន់កាំបិតនៅសាលារៀន នាយកសាលាអាចទូរសព្ទទៅប៉ូលីស។ សិស្សក៏អាចត្រូវបានបណ្ដេញចេញ ឬបញ្ឈប់ពីសាលារៀនភ្លាមៗដែរ។

ការកាន់កាំបិត រួមមានសិស្សម្នាក់ដែលមានកាំបិតដាក់ក្នុងកាបូប ឬទូចាក់សោរបស់ពួកគេ ទោះបីជាពួកគេមិនបានប្រើវា ឬគំរាមកំហែងនរណាម្នាក់ជាមួយវាក៏ដោយ។ ការមានកាំបិតសម្រាប់ការពារខ្លួនក៏ខុសច្បាប់ដែរ។ ការមានកង្វល់ស្ដីពីសុខុមាលភាព ឬសុវត្ថិភាពណាមួយ គួរតែបានបញ្ជូនភ្លាមៗទៅនាយកសាលា។

ឪពុកម្ដាយ និងអ្នកថែទាំត្រូវបានណែនាំមិនឱ្យដាក់កាំបិតលាបប៊ើរ ឬកាំបិតកាត់ផ្លែឈើនៅក្នុងប្រអប់អាហារថ្ងៃត្រង់ ឬឧបករណ៍កាំបិតសម្រាប់គោលបំណងសិប្បកម្មឡើយ។ នៅក្នុងមេរៀនដែលតម្រូវឱ្យប្រើកាំបិត ឧទាហរណ៍ការធ្វើម្ហូប ឬកិច្ចការវិជ្ជាជីវៈ គ្រូរបស់សិស្សនឹងផ្គត់ផ្គង់ ហើយត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍ទាំងនោះ។

សិស្សគ្រប់រូបមានសិទ្ធិដើម្បីមានអារម្មណ៍សុវត្ថិភាព និងសន្តិសុខនៅសាលារៀន។ មិនមានហេតុផលល្អសម្រាប់សិស្ស ដែលត្រូវមានកាំបិតនៅសាលារៀនទាល់តែសោះ។

មានមុខវិជ្ជាសម្រាប់សិស្សថ្នាក់ខ្ពស់មួយចំនួន ដូចជាបដិសណ្ឋារកិច្ច ដែលសិស្សអាចតម្រូវឱ្យមានកាំបិតផ្ទាល់ខ្លួន។ សាលារៀននឹងផ្ដល់ដំបូន្មានដល់ឪពុកម្ដាយ អ្នកថែទាំ និងសិស្ស អំពីវគ្គសិក្សាទាំងនេះ និងនីតិវិធីសម្រាប់ការយកកាំបិតជាប់តាមខ្លួនដោយស្របច្បាប់ ទៅ និងពីសាលារៀន។

## ការដាក់ទណ្ឌកម្មកាន់តែតឹងរ៉ឹងត្រូវអនុវត្ត

ច្បាប់ធ្វើឱ្យឪពុកម្ដាយ និងអ្នកថែទាំទទួលខុសត្រូវ។ ឪពុកម្ដាយ និងអ្នកថែទាំត្រូវប្រាកដច្បាស់ថា កូនរបស់ពួកគេយល់ដឹងអំពីវិន័យរបស់សាលារៀន និងច្បាប់រដ្ឋអំពីកាំបិត។

ឪពុកម្ដាយ និងអ្នកថែទាំត្រូវយល់ដឹងអំពីច្បាប់ទាំងនេះ ពីព្រោះពួកគេអាចជាប់បទចោទប្រកាន់ ប្រសិនបើពួកគេអនុញ្ញាតឱ្យកូនរបស់ពួកគេកាន់កាំបិត។

ប៉ូលីសអាចឆែកឆេរយុវជនណាម្នាក់ ដែលពួកគេសង្ស័យថាមានកាំបិត ហើយអាចរឹបអូសវត្ថុគ្រោះថ្នាក់ណាមួយ ដែលពួកគេអាចរកឃើញក្នុងអំឡុងពេលឆែកឆេរ។ យុវជនត្រូវតែអនុលោមតាមការឆែកឆេររបស់ប៉ូលីស បើមិនដូច្នោះទេ ពួកគេអាចត្រូវប៉ូលីសចាប់ខ្លួន និងជាប់បទចោទប្រកាន់។

មានការកាត់ទោសធ្ងន់ធ្ងរបំផុតចំពោះការវាយប្រហារគ្នា ឬការគំរាមកំហែងដែលពាក់ព័ន្ធនឹងកាំបិត ឧទាហរណ៍ ប្រសិនបើសិស្សឈ្លោះគ្នា ហើយបណ្ដាលឱ្យនរណាម្នាក់រងរបួសដោយកាំបិត។

ប្រសិនបើសិស្សម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រភេទនេះ ជាមួយយុវជនដទៃទៀត ការកាត់ទោសគឺរឹតតែធ្ងន់ធ្ងរ។ ក្នុងករណីខ្លះ ការជាប់ពន្ធនាគារអាចមានរយៈពេលពី 14 ទៅ 25 ឆ្នាំ។

វាក៏ជាការខុសច្បាប់ផងដែរ ចំពោះនរណាម្នាក់ដែលលក់កាំបិត ទៅឱ្យនរណាម្នាក់មានអាយុតិចជាង 16 ឆ្នាំ។

## ការលើកលែង

អាចមានកាលៈទេសៈនៅពេលដែលតម្រូវឱ្យមានការកាន់កាំបិត ហើយមនុស្សម្នាក់អាចបង្ហាញ 'ហេតុផលសមរម្យ' ចំពោះការកាន់កាំបិត។

'ហេតុផលសមរម្យ' រួមបញ្ចូលទាំង ប៉ុន្តែអាចមានលើសពីនេះ ដែលថាការកាន់កាំបិតគឺ 'ចាំបាច់ដោយសមហេតុផល'សម្រាប់៖

- ការបន្តស្វែងរកការងារស្របច្បាប់ ការអប់រំ ឬការបណ្តុះបណ្តាល
- ការចូលរួមក្នុងការកម្សាន្ត ការលំហែ ឬកីឡាស្របច្បាប់
- គោលបំណងសាសនាពិតប្រាកដ ឬ
- ធ្វើដំណើរទៅ ឬមកពីកន្លែងណាមួយខាងលើ។

### សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅនាយកសាលា។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។

ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។